គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# អបអរសាទរទិវាអន្តរជាតិស្តីពីប្រជាធិបតេយ្យ ១៥ កញ្ញា ២០១១

**ភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១:** នាឱកាសទិវាអន្តរជាតិស្តីពីប្រជាធិបតេយ្យ **គណៈកម្មាធិការដើម្បី ការបោះឆ្នោតដោយសេរី និងយុត្តិធមិនៅកម្ពុជា** ហៅកាត់ថា **ខុមហ្វ្រែល** សូមសម្តែងនូវអំណរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងនាំឱ្យមានប្រជាធិបតេយ្យនៅកម្ពុជា និងសូមធ្វើការតស៊ូមតិសម្រាប់កំណែទំរង់បន្ថែមទៀតដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងកន្លងមក។

ថ្ងៃនេះ គឺជាឱកាសមួយសម្រាប់ប្រទេសកម្ពុជា ក្នុងការបង្ហាញការគាំទ្រដ៏ពេញលេញរបស់ខ្លួន ចំពោះគុណតម្លៃជាសាកលនៃប្រជាធិបតេយ្យ ។ **ខុមហ្វ្រែល** សូមយកឱកាសមួយនេះដើម្បីលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាសូមមេត្តាខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធ្វើកំណែទំរង់ផ្សេងៗ សម្រាប់ជាប្រយោជន៏ដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យ។ លោក **សុក សំអឿន** ប្រធានអង្គការ**ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា** និងជា**អនុប្រធានគណៈកម្មាធិការនាយក ខុមហ្វ្រែល** បានលើកឡើងថា "*នៅកម្ពុជាដំណើរការប្រជាធិបតេយ្យពិតប្រាកដ គឺពឹងផ្អែកលើសេរីភាពក្នុងការបញ្ចេញមតិ និងនីតិរដ្ឋ*" ។

ក្នុងនាមជាអ្នកសង្កេតការណ៏ឯករាជ្យនាំមុខគេលើបញ្ហាបោះឆ្នោតក្នុងប្រទេសកម្ពុជា **ខុមហ្វ្រែល** ធ្វើការតស៊ូមតិឱ្យមានកំណែទំរង់ផ្សេងៗប្រយោជន៏ដើម្បីពង្រឹងដំណើរការប្រជាធិបតេយ្យនៅកម្ពុជា ។ កិច្ចខិតខំប្រឹងប្រែងដែល**ខុមហ្វ្រែល**បាន និងកំពុងធ្វើនាំឱ្យមានជោគជ័យដ៏ត្រចះត្រចង់ និងការទទួលស្គាល់ជាអន្តរជាតិចំពោះនាយកប្រតិបត្តិរបស់អង្គការនេះ គឺលោក **គល់ បញ្ញា** ដែលបានទទួលពានរង្វាន់ **រ៉ាម៉ុន មេហ្គសាយសាយ (Ramon MagSaySay Award)** ដ៏ល្បីល្បាញមួយនេះ។

លោក **គល់ បញ្ញា** លើកឡើងថា " ជោគជ័យនេះគឺបានមកពី ការខិតខំដ៏ខ្លាំងក្លារបស់អង្គការសង្គមស៊ីវិល សមាជិក ខុមហ្វ្រែល គណកម្មាធិការនាយក បណ្តាញសកម្មជន អ្នកស្មគ្រចិត្ត អង្គការដៃគូ និងអ្នកពាក់ព័ន្ធផ្សេងៗ ដែលមានឆន្ទៈមោះ មុតក្នុងការធ្វើសកម្មភាពដើម្បីការបោះឆ្នោតមួយសេរី យុត្តិធម និងឱ្យមានអត្ថន័យ។ សកម្មភាពទាំងនេះក៏ទទួលបានការយក ចិត្តទុកដាក់ និងការគាំទ្រពីម្ចាស់ជំនួយ និងដៃគូរអភិវឌ្ឍន៍ជាច្រើន។ ពានរង្វាន់នេះ គឺជាការពង្រឹងនូវបុព្វហេតុរបស់យើង ។

ទោះបីជាយ៉ាងនេះក្តី បុព្វហេតុនៃប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ក៏នៅតែប្រឈមនឹងបញ្ហាជាច្រើន ជាពិសេសបញ្ហាពាក់ព័ន្ធនឹងការបញ្ចេញមតិ។ សមាជិកគណបក្សប្រឆាំង អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស ក៏ដូចជាអង្គការ

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.**

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

ក្រៅ រដ្ឋាភិបាលមួយចំនួនផងដែរ ត្រូវបានតុលាការសម្រេចកាត់ទោសដាក់ពន្ធនាគារ ឬផ្អាកសកម្មភាពមួយរយៈពេល ដោយសារតែការបញ្ចេញមតិរបស់ពួកគេបានរិះគន់រាជរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល។

នាឱកាសទិវាអន្តរជាតិស្តីពីប្រជាធិបតេយ្យ **ខុមហ្វ្រែល** សូមធ្វើការអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាសូមឱ្យដក ចោលការចោទប្រកាន់នានាទៅលើបុគ្គលទាំងនោះ ជាប្រយោជន៍ដើម្បីធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសគំរូ នៅក្នុង ដំណើរការប្រជាធិបតេយ្យ ។ **ខុមហ្វ្រែល** ក៏សូមធ្វើការតស៊ូមតិឱ្យមានកំណែទំរង់ផ្សេងៗទៅលើដំណើរការបោះឆ្នោតដើម្បី បង្កើតទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋកម្ពុជា និងគណបក្សនយោបាយទៅលើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**សូមទំនាក់ទំនង ខុមហ្វ្រែល សម្រាប់ព័ត៌មានបន្ថែម ៖**

លោក **ចន្ទ័ ដារិទ្ធ** (អ្នកសម្របសម្រួលកម្មវិធីព័ត៌មាន)

ទូរសព្ទ័លេខ ៖ (៨៥៥-១២) ៨៤៦ ២១១

ការិយាល័យ ៖ (៨៥៥-២៣) ៨៨៤ ១៥០

អ៊ីម៉ែល ៖ comfrel@comfrel.org

<u>បេសកម្ម</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ ការងាររបស់មន្ត្រីជាប់ឆ្នោត។